カンボジア語

# សំណួរដែលត្រូវបានសួរជាច្រើន

## <ការជ្រើសរើសវិទ្យាល័យ>

Q1.
ការបញ្ចប់ការសិក្សានៅវិទ្យាល័យក្រៅម៉ោង(ថេយជិសេយ)ឬវិទ្យាល័យរៀនតាមប្រព័ន្ធប្រៃសណីយ៍នឹងវិទ្យាល័យពេលថ្ងៃពេញម៉ោងតើបានសញ្ញាបត្រដូចគ្នាដែរឬទេ?

A1.
សម្រាប់ការបញ្ចប់ការសិក្សានៅវិទ្យាល័យគឺអាចទទួលបានសញ្ញាបត្រដូចគ្នា។

Q2.
ដើម្បីចូលរៀននៅសាកលវិទ្យាល័យផ្នែកឧស្សាហកម្មតើគួរតែចូលរៀននៅវិទ្យាល័យផ្នែកឧស្សាហកម្មដែរឬទេ?

A2.
ទោះបីជាអ្នកមិនបានរៀននៅវិទ្យាល័យផ្នែកឧស្សាហកម្មក៏អាចទៅរៀននៅមហាវិទ្យាល័យផ្នែកឧស្សាហកម្មបានដែរ។សិស្សវិទ្យាល័យផ្នែកឧស្សាហកម្មឬផ្នែកពាណិជ្ជកម្មភាគច្រើនក្រោយពេលបញ្ចប់ការសិក្សាតែងតែរកការងារធ្វើ (ជាបុគ្គលិកពេញម៉ោង)
អ្នកដែលមានគោលបំណងទៅរៀននៅមហាវិទ្យាល័យភាគច្រើនគឺជ្រើសរើសយកវិទ្យាល័យទូទៅ។

Q3.
តើខ្ញុំអាចទទួលបានការងារ (ជាបុគ្គលិកពេញម៉ោង) ដោយមិនបានចូលរៀននៅវិទ្យាល័យដែរឬទេ?

A3.
ចំនួនក្រុមហ៊ុនដែលទទួលអ្នកបញ្ចប់ការសិក្សាត្រឹមអនុវិទ្យាល័យអោយចូលធ្វើការមានកំណត់និងតិចតួចណាស់(ជាបុគ្គលិកពេញម៉ោង) ។ ការងារភាគច្រើនទាមទារឱ្យមានសញ្ញាបត្រចាប់ពីវិទ្យាល័យឡើងទៅ។

Q4.
សូមប្រាប់អំពីរបៀបជ្រើសរើសវិទ្យាល័យ។

A4.
・ការជ្រើសរើសវិទ្យាល័យសូមពិចារណាថា"
តើការសិក្សានោះមានប្រយោជន៍សម្រាប់ពេលអនាគតរបស់អ្នកដែរឬទេ?"
តើសមស្របទៅនឹងកម្រិតសិក្សារបស់អ្នកដែរឬទេ"
"តើមានប្រព័ន្ធជំនួយគ្រប់គ្រាន់ផ្នែកភាសាជប៉ុនដែរឬទេ?"

・ការស្តាប់បទពិសោធន៍របស់សិស្សច្បងក៏ជាការល្អក្នុងការយកទៅពិចារណាដែរ។

・សូមចូលរួមធ្វើទស្សនកិច្ចនឹងស្តាប់កិច្ចណែនាំរបស់វិទ្យាល័យដែលអ្នកគិតថានឹងប្រឡងចូល។

・ការស្នើសុំផ្លាស់ប្តូរសាលាបន្ទាប់ពីបានដាក់ពាក្យប្រឡងរួចរាល់ម្តងហើយគឺត្រូវធ្វើអោយបានឆាប់រហ័ស (សូមមើល នៅ**Q7**) ដូច្នេះសូមជ្រើសរើសយកវិទ្យាល័យចំនួន ៣ ទុកជាមុន។

Q5.
ដើម្បីអោយបានចូលរៀននៅមហាវិទ្យាលយ័តើខ្ញុំគួរទៅរៀននៅវិទ្យាល័យបែបណា?

A5.
សូមអានសៀវភៅណែនាំស្តីពីការប្រលងចូលដែលមានលក់នៅតាមទីផ្សារឬក៏មើលនៅគេហទំព័ររបស់វិទ្យាលយ័នីមួយៗស្តីពី「ការបន្តការសិក្សា」
ហើយពិនិត្យមើលថាតើសិស្សច្បងដែលបានបញ្ចប់ការសិក្សានៅវិទ្យាលយ័នោះបានចូលរៀននៅមហាវិទ្យាលយ័បែបណា។ជាទូទៅវិទ្យាល័យដែលយកពិន្ទុសរុប
ឬពិន្ទុប្រឡងចូលខ្ពស់ភាគច្រើនមានសិស្សដែលបន្តការសិក្សាទៅមហាវិទ្យាល័យច្រើន។

※ពន្ទុសរុបគឺសំដៅលើការយកពន្ទុសរុបគ្រប់មុខវិជ្ជាដែលរៀននៅអនុវិទ្យាលយ័។ ឆ្នាំទី2គឺក្នុង1មុខវិជ្ជា5ពិន្ទុ x 9មុខវិជ្ជា + ឆ្នាំទី3គឺត1មុខវិជ្ជា 10 ពិន្ទុ x 9មុខវិជ្ជា។ពិន្ទុសរុបខ្ពស់បំផុតគឺ 135ពិន្ទុ។

※ពិន្ទុប្រលងចូលត្រូវបានគណនាដោយគិតជាមធ្យមភាគរបស់ពិន្ទុសិស្សទាំងអស់ដែលប្រលងចូលវិទ្យាលយ័ហើយកំណត់ពិន្ទុប្រឡងចំនួន50 ។ មធ្យមភាគពិន្ទុប្រឡងខុសគ្នាអាស្រ័យលើវិទ្យាល័យ។ វិទ្យាល័យខ្លះមានគឺមានខ្ពស់ដល់ទៅខ្ទង់70ជាដើម។

Q6.
ពិន្ទុនៅវិទ្យាល័យមិនល្អទេ។ តើមានវិទ្យាលយ័ដែលអាចចូលបានទេ?

A6.
យោងតាមពិន្ទុសរុប(នៅអនុវិទ្យាលយ័)អាចដឹងថាអ្នកអាចមានសមត្ថភាពចូលវិទ្យាលយ័ណា។បើពិន្ទុសរុបមិនគ្រប់គ្រាន់ទេអ្នកត្រូវយកពិន្ទុអោយបានច្រើនក្នុងការប្រឡងចំណេះដឹងទូទៅនឹងការសម្ភាសន៍ជាដើម។

・ចំពោះជនបរទេសដែលរស់នៅក្នុងខេត្តហើយដាក់ពាក្យតាមលក្ខណះពិសេស តាមវិទ្យាលយ័ភាគច្រើនមិនធ្វើការវាយតម្លៃទៅលើពិន្ទុនៅអនុវិទ្យាលយ័(លិខិតអង្កេតការសិក្សា)ឡើយ។

・សាលាវិទ្យាលយ័ហៅថាcreative schoolគឺមិនត្រូវការអោយប្រឡងចំណេះដឹងទូទៅទេ។

・សូមគិតទុកមុនអំពីការដាក់ពាក្យដំណាក់កាលទី2ឬក៏ដាក់ពាក្យចូលវិទ្យាលយ័ក្រៅម៉ោង(ថេយជិសេយ)

Q7.
តើការស្នើសុំផ្លាស់ប្តូសាលាដែលត្រូវប្រឡងចូលត្រូវធ្វើនៅពេលណា?

A7.

・ក្រោយពីដាក់ពាក្យប្រឡងរួចរាល់ហើយត្រូវមើលពិនិត្យសេចក្តីប្រកាសនៅលើកាសែតអំពី「ស្ថានភាពដាក់ពាក្យ」「ការជ្រើសរើសចំនួនសិស្ស」「ចំនួនសិស្សដែលដាក់ពាក្យ」ហើយយកមកថ្លឹងថ្លែងថាតើសមត្ថភាពអ្នកអាចទៅរួចឬក៏ត្រូវផ្លាស់ប្តូសាលាដែលត្រូវប្រឡងចូល? នៅពេលធ្វើការសម្រេចចិត្តសូមពិគ្រោះជាមួយឪពុកម្តាយ,អ្នកជំនួយការនិងគ្រូអនុវិទ្យាល័យរបស់អ្នក។
បន្ទាប់ពីមានសេចក្តីប្រកាសក្នុងកាសែតនឹងការស្នើសុំផ្លាស់ប្តូសាលាដែលត្រូវប្រឡងចូលគឺមិនសូវមានពេលច្រើនទេ។
ហេតុដូច្នេះដើម្បីកុំអោយខាតពេលសូមប្រុងប្រៀបចិត្តឬគិតទុកជាមុននៅពេលដាក់ពាក្យប្រឡង។

Q8.

តើត្រូវធ្វើដូចម្តេចនៅពេលដែលចង់ស្នើសុំផ្លាស់ប្តូសាលាដែលត្រូវប្រឡងចូល?

A8.

ចាំបាច់ត្រូវអោយអាណាព្យាបាលប្រាប់ទៅគ្រូអនុវិទ្យាល័យ។បើមានគំរោងផ្លាស់ប្តូសាលាដែលត្រូវប្រឡងចូលសូមកុំភ្លេចប្រាប់គ្រូនៅពេលដែលមានកិច្ចជំនុំ3នាក់រវាងគ្រូសិស្សនឹងអាណាព្យាបាល។

Q9.

គ្រូអនុវិទ្យាល័យបានណែនាំអោយដាក់ពាក្យ(併願)ចូលវិទ្យាល័យឯកជន។តើគួរដាក់ពាក្យ(併願)ដែរឬទេ?

A9.

ប្រសិនបើអ្នកមានវិទ្យាល័យរដ្ឋដែលអ្នកពិតជាចង់ទៅហើយមិនសូវមានសង្ឃឹមថាប្រឡងជាប់នោះសូមពិចារណាដាក់ពាក្យទៅវិទ្យាល័យឯកជន។
ប្រសិនបើអ្នកប្រឡងជាប់វិទ្យាល័យឯកជនហើយធ្លាក់វិទ្យាល័យរដ្ឋអ្នកត្រូវតែទៅរៀននៅវិទ្យាល័យឯកជនដែលអ្នកបានប្រឡងជាប់។ សូមមេត្តាជ្រាបថាវិទ្យាល័យឯកជនចំណាយប្រាក់ច្រើនណាស់។ ទោះបីជាមានប្រពន្ធ័ឧបត្ថម្ភថ្លៃសិក្សាក៏ដោយតែត្រូវការចំណាយផ្សេងៗជាច្រើនទៀត។

・មិនចាំបាច់ដាក់ពាក្យ(併願)ចូលវិទ្យាល័យឯកជនក៏មានការជ្រើសរើសការដាក់ពាក្យប្រឡងដំណាក់កាលទី2របស់វិទ្យាល័យរដ្ឋឬក៏វិទ្យាល័យក្រៅម៉ោង(ថេយជិសេយ)ដែរ។ គួរដាក់ពាក្យ(併願)ឬក៏អត់សូមពិភាក្សាជាមួយអាណាព្យាបាលអោយបានច្បាស់លាស់។

## ＜ការជ្រើសរើសតាមលក្ខណះពិសេស＞

Q10.

មិនដឹងថាខ្លួនអាចមានសិទ្ធិដាក់ពាក្យតាមលក្ខណះពិសេសសំរាប់សិស្សបរទេសដែលរស់នៅក្នុងខេត្តឬអត់ទេ

A10.

សូមអានសៀវភៅណែនាំនៅលើនៃទំពរ័ទី5ពិនិត្យមើលស្តីពីសិទ្ធិដាក់ពាក្យ។បើនៅមិនបាត់ឆ្ងល់សូមទាក់ទងទៅក្រុមប្រឹក្សាភិបាលអប់រំប្រចាំខេត្តកាណាហ្គាវ៉ា(មានរូបផែនទីនៅលើទំពរ័ទី18នៃសៀវភៅណែនាំ)។

Q11.

បានទៅរស់នៅបរទេស2ឆ្នាំតែអាណាព្យាបាលរស់នៅក្នុងប្រទេសជប៉ុន
តើអាចដាក់ពាក្យតាមលក្ខណះពិសេសសំរាប់សិស្សដែលត្រលប់មកពីបរទេសដែរឬទេ?

A11.

ការដាក់ពាក្យតាមលក្ខណៈពិសេសសំរាប់សិស្សដែលត្រលប់មកពីបរទេសគឺចំពោះតែសិស្សដែលត្រូវបានអាណាព្យាបាលផ្លាស់ប្តូទីតាំងការងារទៅក្រៅប្រទេស
ហើយកូនដែលជាសិស្សនោះទៅរស់នៅបរទេសតាមអាណាព្យាបាលដែរ។ប្រសិនបើសិស្សទៅរស់នៅបរទេសតែឯងគឺចាត់ទុកថាជាសិស្សទៅរៀនក្រៅប្រទេសគឺមិនអាចដាក់ពាក្យតាមលក្ខណៈពិសេសទេ។ក្នុងករណីមានមូលហេតុចាំបាច់ដែលសិស្សត្រូវទៅរស់នៅបរទេសតែឯងសូមពិភាក្សាជាមួយក្រុមប្រឹក្សាភិបាលអប់រំប្រចាំខេត្តកាណាហ្គាវ៉ា។

Q12.

ក្នុងករណីធ្វើអោយបាត់លិខិតឆ្លងដែនហើយមិនមាននៅសល់លិខិតឆ្លងដែនចាស់,ឬមួយក៏មិនមានត្រាចេញចូលប្រទេសជប៉ុននៅលើលិខិតឆ្លងដែន។តើត្រូវធ្វើយ៉ាងណា?

A12.

ត្រូវមាន「លិខិតកំណត់ត្រាចេញចូលប្រទេស」
ធ្វើឡើងដោយក្រសួងយុត្តិធម៍របស់ប្រទេសជប៉ុន។អ្នកអាចដាក់ពាក្យតាមគេហទំពរ៍របស់ក្រសួងយុត្តិធម៍ហើយទទួលលិខិតបញ្ជាក់តាមប្រៃសណីយ៍។អាចចំណាយពេលដល់ទៅ1ខែ។
ហេតុដូច្នេះសូមដាក់ពាក្យអោយបានឆាប់ពីចម្ងាយ។

## ＜ការផ្លាស់ប្តូសាលា＞

Q13.

ក្នុងករណីរៀនចប់ថ្នាក់ទី1នៅឯបរទេសហើយមកប្រទេសជប៉ុន,តើអាចផ្លាស់ប្តូចូលវិទ្យាល័យជប៉ុនបានដែរឬទេ?

A13.

បើបានរៀនចប់ថ្នាក់ទី1នៅបរទេសហើយគឺអាចផ្លាស់ប្តូរមកចូលវិទ្យាល័យជប៉ុនបាន។
ក៏ប៉ុន្តែសាលាដែលអាចចូលបាននឹងរដូវកាលដែលត្រូវចូលគឺមានការកំណត់។ប្រសិនបើមិនសូវចេះជប៉ុនទេអាចគ្មានជំនួយការភាសាជប៉ុនធ្វើអោយអ្នករៀនមិនទាន់គេនៅវិទ្យាល័យថ្នាក់ទី1។សូមអាននៅលើទំព័រទី18នៃសៀវភៅណែនាំហើយធ្វើការពិភាក្សាជាមួយ「មជ្ឈមណ្ឌលព័ត៌មានសម្រាប់ការផ្លាស់ប្តូសាលា」

## ＜ផ្សេងៗ＞

Q14.

មិនចេះអំពីរបៀបរៀន។សូមជួយប្រាប់

A14.

សម្រាប់អ្នកដែលពិបាកក្នុងការរៀនតែឯងឬមិនអាចទៅរៀនគួគឺមានថ្នាក់បង្រៀនបន្ថែមនៅតាមតំបន់រស់នៅ។ថ្នាក់ទាំងនោះភាគច្រើនបង្រៀនដោយឥតគិតថ្លៃ។សូមមើលលើឯកសារ「តារាងឈ្មោះនៃថ្នាក់រៀនបន្ថែម」

Q15.

ការធ្វើសកម្មភាពក្លិបអាចមានគុណសម្បត្តិសម្រាប់ការសម្ភាសន៍ដែរឬទេ?

A15.
បានធ្វើសកម្មភាពក្លិបនៅអនុវិទ្យាល័យហើយបានទៅចូលរួមប្រកួតតាមខេត្តឬក៏បានទទួលពានរង្វាន់ក៏មិនអាចមានការវាយតម្លៃនៃគុណភាពភ្លាមៗចំពោះការសម្ភាសន៍ដែរ។អ្នកត្រូវរៀបរាប់អោយលម្អិតថាតើបានប្រឹងប្រែងអ្វីខ្លះនៅក្នុងសកម្មភាពក្លិប។

Q16.
សូមប្រាប់ឈ្មោះវិទ្យាល័យដែលអាចរៀនជាភាសាអង់គ្លេស។

A16.
រាល់សាលារដ្ឋក្នុងខេត្តកាណាហ្គាវ៉ាមិនមានវិទ្យាល័យណាដែលបង្រៀនជាភាសាអង់គ្លេសទេ។ក៏ប៉ុន្តែមានវិទ្យាល័យមួយចំនួនដែលពង្រឹងមុខវិជ្ជាភាសាអង់គ្លេស។